# ការគ្រប់គ្រងការសម្អាតរុក្ខជាតិឱ្យកាន់តែប្រសើរ

ដើម្បីប្រឈមនឹងការកើនឡើងនៃការគំរាមកំហែងដោយភ្លើងឆេះព្រៃ PG&E កំពុងខិតខំបំពេញការងាររៀងរាល់ថ្ងៃ ដើម្បីពង្រឹងសុវត្ថិភាពនៃប្រព័ន្ធអគ្គិសនីរបស់យើង និងកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃ។

ផែនការរបស់ PG&E ក្នុងការកាត់បន្ថយហានិភ័យនៃភ្លើងឆេះព្រៃដែលអាចកើតមាន រួមមានការអនុវត្តតាម និងការអនុវត្តប្រសើរជាងស្តង់ដារសុវត្ថិភាព និងការសម្អាតរុក្ខជាតិរបស់រដ្ឋ នៅក្នុងតំបន់ដែលយើងផ្តល់សេវាកម្ម។

រដ្ឋកាលីហ្វ័រញ៉ាតម្រូវឱ្យយើងសម្អាតរុក្ខជាតិឱ្យបានត្រឹមត្រូវនៅជុំវិញបណ្តាញចែកចាយថាមពលរបស់យើង នៅក្នុងតំបន់ដែលរដ្ឋបានកំណត់ថាមានហានិភ័យនៃភ្លើងឆេះព្រៃខ្ពស់ ឬខ្ពស់បំផុត។

ឆ្លើយតបនឹងលក្ខខណ្ឌតម្រូវនេះ យើងបានពង្រីក និងពង្រឹងលើកិច្ចការការពារសុវត្ថិភាពពាក់ព័ន្ធនឹងការសម្អាតរុក្ខជាតិ ដើម្បីកម្ចាត់រុក្ខជាតិ ដែលអាចបង្កហានិភ័យខ្ពស់នៅក្នុងតំបន់ដែលមានការគំរាមកំហែងដោយភ្លើងឆេះខ្ពស់។

កិច្ចការគ្រប់គ្រងការសម្អាតរុក្ខជាតិឱ្យកាន់តែប្រសើររបស់យើងត្រូវបាន អនុវត្តលើសស្តង់ដាររបស់រដ្ឋចំពោះការសម្អាតរុក្ខជាតិជាអប្បបរមានៅជុំវិញបណ្តាញថាមពល រួមទាំងការតម្រឹមវល្លិ និងមែកឈើនៅលើបណ្តាញថាមពល ធ្វើការត្រួតពិនិត្យលើសពីទម្លាប់ត្រួតពិនិត្យជាប្រចាំ ដើម្បីយករុក្ខជាតិដែលមានគ្រោះថ្នាក់ចេញ ដូចជាដើមឈើងាប់ មានជំងឺ ជិតងាប់ ឬខូចជាដើម ដែលអាចបង្កផលប៉ះពាល់ដល់ឧបករណ៍ និងបណ្តាញថាមពល។

កិច្ចការនេះត្រូវបានអនុវត្តពេញមួយឆ្នាំ ដើម្បីជួយគាំទ្រដល់ការអនុលោមឱ្យស្របតាមស្តង់ដាររបស់រដ្ឋ។

នៅក្នុងឆ្នាំ 2019 កម្មវិធីសម្អាតរុក្ខជាតិឱ្យកាន់តែប្រសើររបស់យើងបានកាប់ ជម្រះ ឬតម្រឹមរុក្ខជាតិនានានៅជុំវិញបណ្តាញចែកចាយថាមពលជិត 2,500 ម៉ាយល៍។

នៅក្នុងឆ្នាំ 2020 និងបន្ទាប់ពីនេះ ដើម្បីជាផ្នែកមួយនៃកិច្ចប្រឹងប្រែងរយៈពេលច្រើនឆ្នាំ កិច្ចការគ្រប់គ្រងការសម្អាតរុក្ខជាតិឱ្យកាន់តែប្រសើររបស់យើងនឹងបន្តនៅពាសពេញតំបន់ដែលយើងផ្តល់សេវាកម្ម ផ្សេងទៀតដែលរងការគំរាមកំហែងដោយភ្លើងឆេះខ្ពស់ ដោយបញ្ចប់ការសម្អាតនៅបណ្តាញចែកចាយថាមពលក្នុងចម្ងាយ 1800 ម៉ាលយ៍បន្ថែមក្នុងមួយឆ្នាំៗ។

កិច្ចការនេះគឺជាវិធានការសកម្មមួយក្នុងចំណោមវិធានការជាច្រើនដែល PG&E កំពុងអនុវត្តសម្រាប់ជាផ្នែកមួយនៃកម្មវិធីការពារសុវត្ថិភាពពីភ្លើងឆេះព្រៃក្នុងសហគមន៍ទូលំទូលាយរបស់យើង ដែលរួមបញ្ចូលផែនការរយៈពេលខ្លី មធ្យម និងយូរអង្វែង ដើម្បីជួយឱ្យប្រព័ន្ធទាំងមូលរបស់យើងកាន់តែមានសុវត្ថិភាពចាប់ពី Bakersfield រហូតដល់ Eureka។

ការគ្រប់គ្រងការសម្អាតរុក្ខជាតិឱ្យកាន់តែប្រសើររបស់យើងត្រូវបានធ្វើឡើងបន្ថែមពីលើកម្មវិធីគ្រប់គ្រងការសម្អាតរុក្ខជាតិជាប្រចាំរបស់យើង។

ដើម្បីការពារសុវត្ថិភាពសាធារណៈ យើងកំពុងចាត់វិធានការរៀងរាល់ថ្ងៃ ដើម្បីពង្រឹងសុវត្ថិភាព និងទំនុកចិត្តនៃប្រព័ន្ធអគ្គិសនីរបស់យើង។

ចំណុចនេះរួមទាំងការសហការជាមួយអតិថិជន និងសហគមន៍នានា ដើម្បីគ្រប់គ្រងដើមឈើ និងរុក្ខជាតិផ្សេងទៀត ដែលស្ថិតនៅជិតបណ្តាញថាមពល ដែលអាចបង្កឱ្យមានភ្លើងឆេះព្រៃ ឬការដាច់ភ្លើង។

កម្មវិធីគ្រប់គ្រងការសម្អាតរុក្ខជាតិជាប្រចាំរបស់យើងត្រួតពិនិត្យបណ្ដាញថាមពលនៅលើដីប្រហែល 100,000 ម៉ាយល៍ក្នុងមួយឆ្នាំ រួមជាមួយការត្រួតពិនិត្យតំបន់មួយចំនួនជាច្រើនដងក្នុងមួយឆ្នាំ ជម្រះ ឬកាប់ដើមឈើជាង 1 លានដើមរៀងរាល់ឆ្នាំ ដើម្បីសម្អាតតំបន់នៅជុំវិញបណ្ដាញថាមពល ព្រមទាំងកាប់ដើមឈើងាប់ មានជំងឺ ជិតងាប់ ឬខូច នៅតំបន់ដែលទទួលរងប៉ះពាល់ដោយគ្រោះរាំងស្ងួត និងសត្វកញ្ចែស៊ីដើមឈើ។

ចាប់តាំងពីឆ្នាំ 2014 យើងក៏បានផ្ដល់មូនិធិជាង 15 លានដុល្លារ
ដើម្បីគាំទ្រដល់ក្រុមប្រឹក្សាការពារសុវត្ថិភាពពីភ្លើងឆេះក្នុងតំបន់ផងដែរ
ដើម្បីជួយដល់កិច្ចប្រឹងប្រែងរបស់ពួកគេក្នុងការពង្រឹងសុវត្ថិភាពពីភ្លើងឆេះនៅក្នុងសហគមន៍។

គម្រោងរបស់ក្រុមប្រឹក្សាការពារសុវត្ថិភាពពីភ្លើងឆេះដែលទទួលបានមូលនិធិទាំងនេះរួមបញ្ចូលការបង្កើតបន្ទាត់ ឬចន្លោះទប់ស្កាត់ការរាលដាលភ្លើងឆេះ ព្រមទាំងកែលម្អផ្លូវគេចខ្លួនពីភ្លើងឆេះ
និងផ្លូវដែលអាចចូលបានពេលមានអាសន្ន។

ដើមឈើគឺជាផ្នែកដ៏សំខាន់មួយ ដែលធ្វើឱ្យបរិស្ថានធម្មជាតិនៅភាគខាងជើង
និងភាគកណ្ដាលនៃរដ្ឋកាលីហ្វ័រញ៉ាភាពលក្ខណៈពិសេស និងស្រស់ស្អាត។

PG&E ឱ្យតម្លៃ និងស្រលាញ់ដើមឈើ និងបរិស្ថានធម្មជាតិ។

ទោះបីជាយ៉ាងនេះក្ដី ដើមឈើដែលគំរាមកំហែង ឬស្ថិតនៅជិតបណ្ដាញថាមពលពេក អាចបង្កគ្រោះថ្នាក់
និងធ្វើឱ្យសហគមន៍ដែលយើងបម្រើសេវា ប្រឈមនឹងហានិភ័យនៃភ្លើងឆេះព្រៃ។

យើងទាំងអស់គ្នាពឹងផ្អែកលើអគ្គិសនីរៀងរាល់ថ្ងៃ ហើយយើងនឹងបន្តសហការជាមួយអតិថិជនរបស់យើង
ដើម្បីស្វែងរកដំណោះស្រាយដែលអាចទប់ស្កាត់ភ្លើងឆេះព្រៃទ្រង់ទ្រាយធំ
និងជួយរក្សាសុវត្ថិភាពសម្រាប់សហគមន៍របស់យើង។

ដើម្បីទទួលបានព័ត៌មានថ្មីបំផុតអំពីកិច្ចប្រឹងប្រែងការពារសុវត្ថិភាពពីភ្លើងឆេះព្រៃរបស់ PG&E សូមចូលទៅកាន់ pge.com/cwsp។